# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលមាត្រា៨ និងមាត្រា៥៩ នៃអនុក្រឹត្យ
## លេខ១០៣ អនក្រ បក ចុះថ្ងៃទី២៩ ខែធ្នូ
## ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...៧០...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលមាត្រា ៨ និង មាត្រា ៥៩ នៃអនុក្រឹត្យលេខ ១០៣ អនក្រ បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១/៩៧/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ៥៦ ក្រ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៨៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី សញ្ជាតិ
- បានឃើញព្រះរាជក្រមលេខ នស. រកម/០៣០១.០៥ ចុះថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ១០៣ អនក្រ បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន
- យោងតាមតាមសំណើរបស់គណៈកម្មាធិការជាតិគាំទ្រ ឃុំ សង្កាត់

## ស ម្រ េ ច

**មាត្រា១** .- ត្រូវបានកែសម្រួលមាត្រា ៨ និង មាត្រា ៥៩ នៃអនុក្រឹត្យលេខ ១០៣ អនក្រ បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋានដូចខាងក្រោម ៖

**មាត្រា ៨ ថ្មី..**

ក្រុមប្រឹក្សា ឃុំ សង្កាត់ ទទួលខុសត្រូវការងារអត្រានុកូលដ្ឋានក្នុងដែនដី ឃុំ ឬ សង្កាត់ ដែលខ្លួនគ្រប់គ្រង ។

មេឃុំ ចៅសង្កាត់ជាមន្ត្រីអត្រានុកូលដ្ឋាន ។

**មាត្រា ៥៩ ថ្មី..**

ការសុំបញ្ជាក់អត្រានុកូលដ្ឋានមានចុះ សៀវភៅបញ្ជាក់កំណើត សៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ សៀវភៅបញ្ជាក់មរណភាព ត្រូវបានអនុវត្តចំពោះតែលើពលរដ្ឋខ្មែរ ហើយអនុវត្តតែក្នុងរយៈពេល ៣ ឆ្នាំ ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០២ រហូតដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៥ ។

ផុតរយៈពេលនេះ ពលរដ្ឋខ្មែរដែលគ្មានសំបុត្រអត្រានុកូលដ្ឋានកំណើត និង មរណភាពត្រូវទៅសុំសាលក្រម ពីតុលាការ ខេត្ត ក្រុង សាមី រួចយកសាលក្រមនោះ មកសុំមន្ត្រីអត្រានុកូលដ្ឋាន ឃុំ ឬ សង្កាត់ ដើម្បីចុះសៀវភៅអត្រានុកូលដ្ឋាន។ ឯការបញ្ជាក់អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍អនុញ្ញាតអោយប្តីប្រពន្ធសុំចុះតាមការស្ម័គ្រចិត្តនៃសហព័ទ្ធ ។

សំរាប់ ឆ្នាំ ២០០២ សៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទត្រូវបានអនុញ្ញាតអោយបើកប្រើប្រាស់ចាប់ពីថ្ងៃទី ០១ ខែ សីហា ហើយត្រូវបញ្ឈប់នៅ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០២ ។

ចាប់ពីឆ្នាំ ២០០៣ តទៅត្រូវអនុវត្តបទបញ្ញត្តិដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ១៤ នៃអនុក្រឹត្យ លេខ ១០៣ អនក្រ បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០២*

**នាយករដ្ឋមន្ត្រី**

បានយកសេចក្តីជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
**សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង          យូ ហុកគ្រី**

**ចម្លងជូន**
- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- កាលប្បវត្តិ ឯកសារ

សរ225